# ការិយាល័យនៃនាយកដ្ឋានផែនការ និងការអភិវឌ្ឍ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

## គោលការណ៍ណែនាំសម្រាប់កម្មវិធីកែលម្អផ្នែកខាងមុខហាង

### ពិពណ៌នាអំពីកម្មវិធី

កម្មវិធីកែលម្អផ្នែកខាងមុខហាង គឺជាកម្មវិធីមួយដែលផ្តល់ថវិកាជំនួយផ្គូផ្គង (matching grants) សម្រាប់ម្ចាស់អគារ ឬអ្នកជួល ដែលចង់កែលម្អ ឬសង់ឡើងវិញនៅផ្នែកខាងមុខនៃជាន់ផ្ទាល់នៃអគារពាណិជ្ជកម្ម។ កម្មវិធីនេះមានបំណងសម្រួលទីធ្លាឲ្យបើកទូលាយសម្រាប់ចេញចូលនៅខាងមុខហាង កែលម្អសោភ័ណភាពនៃអាជីវកម្មរបស់ម្ចាស់ហាងឯករាជ្យ និងធ្វើឲ្យសង្កាត់ពាណិជ្ជកម្មរបស់ក្រុងឡូវែលកាន់តែល្អប្រសើរឡើង។

កម្មវិធីនេះផ្តល់៖

- ទឹកប្រាក់ផ្គូផ្គង **៩០% ជាថវិកាជំនួយ ដែលមានទឹកប្រាក់រហូតដល់ ២០,០០០ ដុល្លារ សម្រាប់ការកែលម្អច្រកចូលអគារឲ្យងាយស្រួលសម្រាប់ជនពិការ**ផង ដោយរួមមានទាំងការបំពាក់ជម្រាល ជណ្តើរយោង គ្រឿងបំពាក់មាត់ទ្វារ និងមាត់ទ្វារបើកបានដោយស្វ័យប្រវត្តិ កន្លែងចតរថយន្តសម្រាប់ជនពិការផង និងស្លាកសញ្ញា។
- **ទឹកប្រាក់ជំនួយ ៥០% នឹងត្រូវផ្គូផ្គង ដែលមានចំនួនទឹកប្រាក់រហូតដល់ ១៥,០០០ ដុល្លារ សម្រាប់ការកែលម្អខាងមុខហាង** រួមទាំងមាត់បង្អួច លម្អតាមជញ្ជាំង ការបង្ហាញព័ត៌មានលម្អិតអំពីស្ថាបត្យកម្ម និងការស្តារឡើងវិញនូវមរតកវប្បធម៌ប្រវត្តិសាស្ត្រ។
- **ទឹកប្រាក់ជំនួយ ៥០% នឹងត្រូវផ្គូផ្គង ដែលមានចំនួនទឹកប្រាក់រហូតដល់ ២,៥០០ ដុល្លារ សម្រាប់ស្លាកសញ្ញា** រួមទាំងស្លាកសញ្ញានៅតាមបង្អួច ភ្លើងបំភ្លឺ និងសំយាបហាង។

សូមចំណាំថាការកែលម្អ ដែលបានធ្វើនៅមុនមានការឯកភាពអំពីរចនាបទ និងកិច្ចសន្យាពីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចនៃនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ នឹងមិនបានទទួលថវិកាជំនួយនោះឡើយ។ គម្រោងធំៗអាចតម្រូវឲ្យមានអាជ្ញាប័ណ្ណផ្ទៃស្ថាបត្យកម្ម និងម៉ៅការ ដើម្បីពិនិត្យមើលលម្អិតអំពីរចនាបទឲ្យត្រូវតាមស្ថានភាព និងអនុវត្តផែនការដែលមានការឯកភាពជាមុនរបស់សាលាក្រុង។

### ទម្រង់ពាក្យសុំ

ដើម្បីចូលរួមក្នុងកម្មវិធីកែលម្អផ្នែកខាងមុខហាងនេះបាន ម្ចាស់អគារ ឬអ្នកជួលអគារត្រូវតែពិនិត្យមើលគោលការណ៍ណែនាំអំពីកម្មវិធីកែលម្អផ្នែកខាងមុខហាង (នៅខាងក្រោម) និងបំពេញទម្រង់ពាក្យសុំ

ចូលរួមកម្មវិធីនេះ។ ពាក្យសុំអាចបំពេញបានតាមមធ្យោបាយដូចខាងក្រោម៖

តាមអនឡាញ (យើងលើកទឹកចិត្តឲ្យដាក់របៀបនេះ)៖ https://lowellma.gov/1130/Sign-Facade-Grant-Program.

តាមក្រដាស៖ ពាក្យសុំជាក្រដាសមាននៅ៖ https://lowellma.gov/1130/Sign-Facade-Grant-Program ដែលលោកអ្នកអាចបោះពុម្ព និងបំពេញវា។ ពាក្យសុំជាលាយលក្ខណ៍អក្សរនេះ មានទុកនៅ ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច នៃនាយកដ្ឋានផែនការអភិវឌ្ឍន៍ និងអាចមកយកបាននៅក្នុងម៉ោងធ្វើការ គឺនៅថ្ងៃ ចន្ទ ពុធ ព្រហស្បតិ៍ ពីម៉ោង ៨ព្រឹក ដល់ ៥ល្ងាច ថ្ងៃ អង្គារ ពីម៉ោង ៨ព្រឹក ដល់ ៨យប់ និងថ្ងៃ សុក្រ ពីម៉ោង ៨ព្រឹក ដល់ ១២ថ្ងៃត្រង់។ លោកអ្នកត្រូវតែដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរបឋម ដោយយកវាទៅដាក់នៅនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ ឬផ្ញើតាមប៉ុស្តិ៍ប្រៃសនីយ៍ទៅកាន់៖

Department of Planning and Development
Economic Development Office
50 Arcand Drive, 2nd floor
Lowell, MA 01852

## ព័ត៌មានទំនាក់ទំនងសម្រាប់ថវិកាជំនួយ

អ៊ីម៉េល៖ DoBizinLowell@Lowellma.gov

ទូរស័ព្ទ៖ 978-674-4252

## គោលការណ៍ណែនាំ

នាយកដ្ឋានផែនការ និងអភិវឌ្ឍន៍របស់ក្រុងឡូវែល បានបង្កើតកម្មវិធីកែលម្អផ្នែកខាងមុខហាង ដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុដល់ម្ចាស់អគារ ឬអ្នកជួលរកស៊ី ដែលចង់ដោះរបាំងផ្នែកស្ថាបត្យកម្ម កែលម្អផ្នែកខាងមុខនៃអគារពាណិជ្ជកម្ម និងធ្វើឲ្យប្រសើរស្លាកសញ្ញានៅខាងក្រៅហាង។ គោលបំណងនេះកម្មវិធីនេះ គឺដើម្បីកែសម្រួលលទ្ធភាពចេញចូលទាំងសម្រាប់ជនពិការ និងសោភ័ណភាពហាង និងកែលម្អមុខមាត់សង្កាត់ពាណិជ្ជកម្ម។ កម្មវិធីនេះ ផ្តល់នូវថវិកាជំនួយដែលផ្គូផ្គងមួយក្នុងទម្រង់ជាប្រាក់ទូទាត់សងវិញតាមក្រោយ សម្រាប់ការផ្តល់មូលនិធិកែលម្អដែលស្របទៅតាមលក្ខណៈសំខាន់ៗនៃផ្នែកខាងមុខហាង ដើម្បីឲ្យមានសោភ័ណភាពគួរឲ្យទាក់ទាញ ព្រមទាំងបង្កើតឲ្យទីធ្លាខាងមុខហាងនោះអាចចេញចូលបានសម្រាប់សាធារណជនទូទៅ រួមទាំងសម្រាប់ជនពិការផង។ ចំណុចនេះ អាចរួមមានទាំងការដោះរបាំងដែលទើសការធ្វើដំណើរ ការកែលម្អឡើងវិញនូវស្នាដៃស្ថាបត្យកម្មលម្អិត កែលម្អបង្អួច និងមាត់ទ្វារ និងស្លាកសញ្ញាផ្សេង រួមទាំងភ្លើងបំភ្លឺ។ អ្នកដាក់ពាក្យសុំត្រូវទទួលខុសត្រូវ ក្នុងការជួលស្ថាបត្យករ អ្នកម៉ៅការ និងអ្នកធ្វើស្លាកសញ្ញាដែលមានអាជ្ញាប័ណ្ណ។ អ្នកជួលអគារដែលបំពេញគ្រប់លក្ខខណ្ឌសម្រាប់ទទួលបានថវិកាជំនួយ គឺជាស្ថាប័នអាជីវកម្មដែលលក់ទំនិញ និ

ងសេវាដោយផ្ទាល់ទៅឲ្យអតិថិជនទូទៅ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងសម្រាប់ការប្រើប្រាស់ដែលមិនមែនសម្រាប់លក់បន្ត (លក់ដុំ)។ ក្នុងនិយមន័យនៃផ្នែកនេះ គឺមានរួមបញ្ចូលទាំងម្ហូបអាហារ និងអាជីវកម្មថ្មៃប្រឌិតដើម្បីរកប្រាក់កម្រៃ។ ការកែលម្អ ឬការទូទាត់ប្រាក់ទៅឲ្យអ្នកលក់ ដែលបានធ្វើនៅមុនការចុះហត្ថលេខាលើកិច្ចសន្យាទទួលប្រាក់ជំនួយកែលម្អខាងមុខហាង ជាមួយការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច នៃនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ គឺនឹងពុំទទួលបានការទូទាត់ប្រាក់សងវិញ ហើយនឹងត្រូវបានយកមកពិចារណានោះឡើយ។

## លក្ខខណ្ឌសម្រាប់បំពេញ

ខាងក្រោមនេះគឺជាលក្ខខណ្ឌដែលត្រូវអនុវត្តគ្រប់អ្នកដាក់ពាក្យចូលកម្មវិធីកែលម្អខាងមុខហាង និងគម្រោងដែលនឹងកើតមាន៖

1. អ្នកដាក់ពាក្យសុំត្រូវតែជាម្ចាស់អគារ ឬអ្នកជួលអគារពាណិជ្ជកម្ម ដែលផ្នែកខាងមុខនៃហាងរបស់ពួកគាត់ បែរមុខទៅផ្លូវណាមួយក្នុងទីក្រុងឡូវែល។
2. អ្នកជួលអគារសម្រាប់ពាណិជ្ជកម្ម ដែលតែជាអ្នកដែលលក់ទំនិញ ឬផ្តល់សេវាសម្រាប់អតិថិជនទូទៅ។
3. ថវិកាជំនួយនេះទំនងជាផ្តល់ឲ្យទៅខាងអាជីវកម្មដែលមានម្ចាស់កម្មសិទ្ធិដាច់មុខច្រើនជាង និងដែលពួកគាត់មិនចាំបាច់ត្រូវការកិច្ចសន្យាណាមួយ ដើម្បីកែលម្អ និងថែទាំងហាង ស្លាបត្យកម្ម ស្លាកសញ្ញា ឬលក្ខណៈស្រដៀងនេះផ្សេងទៀត។
4. ថវិកាជំនួយនេះទំនងជាផ្តល់ឲ្យទៅខាងអាជីវកម្មដែលមានម្ចាស់ជាអ្នកត្រូវគេមើលរម្លងជាប្រវត្តិសាស្ត្រ (ស្ត្រីមិនមែនជាជនជាតិស្បែកស អតីតយុទ្ធជន ជនទាំងឡាយណាដែលពិការ និងសហគមន៍ក្រុមភេទទីបី)។
5. ថវិកាជំនួយនេះទំនងជាផ្តល់ឲ្យទៅខាងអ្នកជួលសម្រាប់អាជីវកម្ម នៅក្នុងសង្កាត់ ឬច្រកពាណិជ្ជកម្ម។
6. អ្នកជួយអគារ ត្រូវមានលិខិតឯកភាពពីម្ចាស់អគារ ដើម្បីចូលរួមក្នុងកម្មវិធីកែលម្អមុខហាងនេះ និងត្រូវមានលិខិតជួលបច្ចុប្បន្ន ដែលមានរយៈពេលជួលយ៉ាងតិចមួយឆ្នាំ និងមានជម្រើសជួលបន្ត។ ការជួលមួយខែទៅមួយខែ នឹងមិនអាចទទួលយកបានទេ។
7. សំណើសុំកែលម្អ ត្រូវតែជាការកែលម្អអចិន្ត្រៃយ៍ និងឲ្យឃើញនៅខាងមុខហាង (ឧទាហរណ៍ ស្លាកផ្សាយនំសាំងវិច សម្រាប់អ្នកថ្មើរជើង និងគ្រឿងសង្ហារឹមនៅរានហាលខាងមុខ នឹងមិនទទួលយកបានឡើយ)។
8. ផ្ទាំងផ្សាយពាណិជកម្មលើអគារ បើមាន ត្រូវតែរើចេញជាអចិន្ត្រៃយ៍ ដែលជាផ្នែកមួយនៃការកែលម្អ។
9. ម្ចាស់អគារត្រូវតែបង់ពន្ធជូនរដ្ឋឲ្យបានទាន់ពេលវេលា នៅមុនចូលរួមក្នុងកម្មវិធីនេះ។

10. អ្នកដាក់ពាក្យសុំត្រូវតែអនុវត្តតាមច្បាប់ និងបទបញ្ញត្តិរបស់ជាតិ រដ្ឋ និងអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធនឹងការជួល លិខិតអនុញ្ញាត កូដសម្រាប់សាងសង់ បញ្ញត្តិអំពីជនពិការ និងលក្ខខណ្ឌក្នុងការកំណត់តំបន់។
11. អ្នកធ្លាប់ចូលរួមកម្មវិធីកែលម្អខាងមុខហាងពីមុនៗ ដែលបានបំពេញចប់គម្រោងរបស់ខ្លួន និងបានទទួលប្រាក់ទូទាត់វិញ ទៅតាមលក្ខខណ្ឌក្នុងកិច្ចសន្យា អាចដាក់ពាក្យសុំចូលរួមកម្មវិធីនេះជាថ្មីទៀតបាន ក្រោយ ប្រាំ(៥)ឆ្នាំ រាប់ចាប់តាំងពីថ្ងៃទទួលបានថវិកាជំនួយលើកមុន។
12. អ្នកចូលរួមអាចស្នើសុំចូលរួមកម្មវិធីនេះម្តងទៀតបាន នៅមុនផុតរយៈពេលប្រាំ (៥)ឆ្នាំ គិតចាប់ពីថ្ងៃនៃកិច្ចសន្យាដំបូងនោះ ប៉ុន្តែសំណើទាំងនេះ នឹងត្រូវពិនិត្យមើល ទៅតាមករណីជាក់លាក់នីមួយៗ។
13. ដើម្បីឲ្យទទួលបានការពិចារណាក្នុងការផ្តល់ថវិកាជំនួយនេះ នៅមុនរយៈពេល ៥(ប្រាំ)ឆ្នាំនោះ អ្នកដាក់ពាក្យសុំត្រូវបង្ហាញចំណុចណាមួយដូចខាងក្រោម៖
    a. អ្នកដាក់ពាក្យសុំត្រូវបានប្តូរទីតាំង និងរបស់ដែលបានថវិកាជំនួយលើកមុន សម្រាប់កម្មវិធីកែលម្អខាងមុខហាងនោះ មិនអាចយកមកប្រើប្រាស់ឡើងវិញបាននោះឡើយ។
    b. អ្នកដាក់ពាក្យសុំបានបើកហាងកន្លែងទីតាំងថ្មី នៅទីក្រុងឡូវេល និងមានទីតាំងផ្សេងទៀតដែលស្នើសុំថវិកាជំនួយនេះ។
    c. អ្នកដាក់ពាក្យសុំជួបបញ្ហាខ្វះខាត ដោយសារតែស្ថានភាពអាសន្ន ឬគ្រោះមហន្តរាយធម្មជាតិ (ឧទាហរណ៍ ភ្លើងឆេះ ទឹកជំនន់ ចោរលួចគាស់ ជំងឺកូវីដ-១៩) និងការសាងសង់គឺត្រូវធ្វើជាចាំបាច់ ដើម្បីកាត់បន្ថយស្ថានភាពទាំងឡាយ (ឧទាហរណ៍ បង្អួច ឬមាត់ទ្វារដែលបើកសម្រាប់ឲ្យខ្យល់អាកាសចេញចូលច្រើន ឬសម្រាលការលំបាករបស់អតិថិជនក្នុងការបង់ប្រាក់មាត់ទ្វារទាញនៅ ខាងមុខអាជីវកម្ម ដូរបង្អួច ឬមាត់ទ្វារ)។

សាលាក្រុងឡូវែលសូមរក្សាសិទ្ធិ ក្នុងការដាក់ចេញលក្ខខណ្ឌបន្ថែម នៅមុនទទួលយកគម្រោងណាមួយ បើតម្រូវការនៃកម្មវិធី មានទំហំធំលើសធនធានថវិកាកំណត់។

## គោលការណ៍រចនា និងសេចក្តីណែនាំ

ផ្នែកខាងមុខហាង គួរតែរចនាឡើងដើម្បីទាក់ទាញអ្នកថ្មើរជើង និងជួយសម្រួលដល់ការចេញចូលរបស់ជនពិការ ផ្តល់នូវសោភ័ណភាពទាក់ទាញ ទាំងពេលថ្ងៃ និងយប់ និងបង្កើតភាពពិសេសប្លែកពីគេរបស់ហាងក្នុងក្រុងឡូវែល និង/ឬ ឲ្យស័ក្តិសមទៅនឹងស្ថានភាពក្នុងភូមិឋាននោះ។
ថវិកាសម្រាប់កែលម្អដែលបានពីកម្មវិធីនេះ ត្រូវតែស្របគ្នាជាមួយចរិតលក្ខណៈ និងស្ថាបត្យកម្មនៃអគារនីមួយៗ និងត្រូវស៊ីគ្នាទៅនឹងសមាមាត្រជាមួយអគារនៅម្តុំនោះផងដែរ។ អគារដែលមានគុណសម្បត្តិផ្នែកស្ថាបត្យកម្មល្អ គឺជាសំណង់ដែលយើងលើកទឹកចិត្តឲ្យស្តារឲ្យល្អ និងរក្សាលំនៅដើម និងគុណភាពផ្នែកស្ថាបត្យកម្មនេះ។

ការកែលម្អសម្រាប់អាគារ ដែលពុំមានលក្ខណៈសម្បត្តិផ្នែកប្រវត្តិសាស្ត្រ ឬស្ថាបត្យកម្ម គួរតែជាឱកាសមួយសម្រាប់កែសោភ័ណភាពនៃអគារនោះ និងសោភ័ណភាពផ្លូវ។ អាជីវកម្មត្រូវអនុវត្តតាមច្បាប់មូលដ្ឋាន ច្បាប់រដ្ឋ និងច្បាប់ជាតិអំពីលក្ខខណ្ឌសម្រាប់សម្រួលការធ្វើដំណើររបស់ជនពិការ។ ច្បាប់ស្តីពីពលរដ្ឋអាមេរិកដែលពិការ គឺជាច្បាប់ជាតិ ដែលមានចែងអំពីបទដ្ឋានសម្រាប់រចនាបទដែលសម្រួលដល់ជនពិការនេះ ដើម្បីធានាឲ្យបានថាអាជីវកម្មគឺបើកសម្រាប់ឲ្យអ្នកដែលពិការអាចចេញចូលបានផងដែរ។ ក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត (MAAB) គឺជាទីភ្នាក់ងាររបស់រដ្ឋ ដែលមានបទបញ្ញត្តិផ្ទាល់របស់ខ្លួនជុំវិញរឿងសម្របសម្រួលការធ្វើដំណើរសម្រាប់ជនពិការនេះ។ ទោះបទដ្ឋានរបស់ក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត និងបទដ្ឋានស្តីពីការយកចិត្តទុកដាក់ដល់ជនពិការ មានភាពស្រដៀងគ្នាច្រើនប្រការយ៉ាងណាក្តី ក៏នៅមានចំណុចខុសគ្នាមួយចំនួនដែរ។ ក្នុងករណីដែលបទបញ្ញត្តិចែងខុសគ្នា ច្បាប់ដែលយកចិត្តទុកដាក់ខ្លាំងលើការធ្វើដំណើររបស់ជនពិការ គឺជាច្បាប់ដែលត្រូវមានអានុភាពអនុវត្តជាង។ សូមពិនិត្យមើលបទដ្ឋាននៃច្បាប់ស្តីពីពលរដ្ឋអាមេរិកដែលជាជនពិការ និងបទដ្ឋានរបស់ក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត ដើម្បីធ្វើយ៉ាងណាឲ្យលោកអ្នកប្រាកដថា ការកែលម្អណាមួយដែលត្រូវធ្វើ គឺអនុលោមតាមច្បាប់ទាំងនេះ។

1. **ការកែលម្អផ្នែកខាងមុខហាងដែលអាចទទួលយកបាន**

   ការកែលម្អខាងក្រោមនេះ គឺជាអ្វីដែលយើងលើកទឹកចិត្តឲ្យធ្វើ៖

   a. មាត់ទ្វារចូលមុខហាងត្រូវផ្តល់លទ្ធភាពអាចប្រើប្រាស់បានទាំងអស់គ្នា* (ឧទាហរណ៍ ជម្រាលសម្រាប់ជនពិការ ជណ្តើរយោង ។ល។) និងទ្វារដែលផ្តល់លទ្ធភាពអាចប្រើប្រាស់បានទាំងអស់គ្នា* (ឧទាហរណ៍ ទ្វារដែលបើកដោយស្វ័យប្រវត្តិ គ្រឿងឧបករណ៍ដែលអនុលោមតាមច្បាប់ស្តីពីពលរដ្ឋអាមេរិកដែលពិការ និងបញ្ញត្តិរបស់ក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត ។ល។) * ដូចមានចែងត្រង់ M.G.L. c. 22, § 13A, of 521 CMR។

   b. ការស្តារឡើងវិញនូវចំណុចលម្អិតនៃអគារដែលបង្ហាញលក្ខណៈប្រវត្តិសាស្ត្រ ឬដែលមានខ្លឹមសារសំខាន់ជាប្រវត្តិសាស្ត្រ និងការរើសចេញនូវធាតុទាំងឡាយដែលបិទបាំងចំណុចលម្អិតនៃស្នាដៃស្ថាបត្យកម្មទាំងនោះ។

   c. កន្លែងដាក់តាំងនៅមាត់បង្អួច ដែលមានភាពសមាមាត្រ និងដែលជួយដល់សោភ័ណភាពពេលរាត្រី ការដូរបង្អួច និងស៊ុំបង្អួចដែលមើលពីថ្នល់ទៅឃើញ គឺត្រូវធ្វើឲ្យសមស្របតាមទម្រង់អគារ។

d. ស្លាកសញ្ញាដែលមើលទៅគួរឲ្យទាក់ទាញ ដែលស៊ីគ្នាទៅនឹងស្ថាបត្យកម្មនៃអគារនោះ រួមទាំងផ្នែកបង្អួច សំយាប ឬឆ័ត្របាំងកំដៅ និងផ្លូវចូល។
e. ការដាក់ភ្លើងបំភ្លឺ ដែលងាយមើលឃើញ គឺទាក់ទាញ និងការដាក់ស្លាកសញ្ញាដែលមានភ្លើងបំភ្លឺសមល្មម ការដាក់តាំងបង្ហាញនៅបង្អួចខាងមុខ និងផ្នែកខាងក្រៅនៃជញ្ជាំងអគារ។
f. សំយាប ឬឆ័ត្របាំងកំដៅ ដែលអាចមើលទៅប្រើការបាន និងទាក់ទាញ
g. លក្ខណៈសោភ័ណភាពនៃអគារ ដែលមានដាក់តាំងគ្រឿងលម្អសមស្រប ដូចជារងដាំផ្កាក្រោមបង្អួច ឬជើងផ្កា។
h. ការសាងសង់ច្រកចូលថ្មី និងការសាងសង់ផ្នែកខាងមុខហាង ដែលមានសមា ទៅនឹងទំហំរបស់អគារដែលមានស្រាប់។
i. របស់ដែលត្រូវបានឯកភាពរួចផ្សេងទៀត (ឧទាហរណ៍ ផ្ទាំងគំនូរ ការសម្អាត ការប៉ះប៉ូវកន្លែងរបេះខូចខាត ។ល។) ដែលចាំបាច់សម្រាប់ការកែលម្អហាងជាទូទៅ។

ឧទាហរណ៍ ការរើរនាំងរាំងផ្លូវ សូមមើល "The Americans with Disabilities Act Checklist for Readily Achievable Barrier Removals" តាមគេហទំព័រនេះ៖ www.ada.gov/racheck.pdf និង "ADA Guide for Small Businesses" តាមគេហទំព័រនេះ៖ www.ada.gov/smbusgd.pdf ចំណុចលម្អិតអំពីក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត អាចរកបាននៅគេហទំព័រនេះ៖ https://www.mass.gov/aab-rules-and-regulations។

**ការកែលម្អពីមុន**

ការកែ ឬកែលម្អ ឬការទូទាត់ប្រាក់ទៅអ្នកលក់ ដែលបានធ្វើឡើងនៅមុនទទួលបានកិច្ចសន្យាទូទាត់ប្រាក់សងវិញ ឬ "សេចក្តីជូនដំណឹងអំពីការអនុញ្ញាតឲ្យដំណើរការកែលម្អ" ពីសាលាក្រុង គឺត្រូវចាត់ទុកថាមិនអាចទទួលយកបានសម្រាប់ការផ្តល់ប្រាក់ទូទាត់សងវិញនេះទេ។ អ្នកដាក់ពាក្យសុំត្រូវព្រមព្រៀងថាមិនកែប្តូរ ឬកែផ្នែកខាងក្រៅរបស់អគារដែលបានកែលម្អនោះ នៅមុនមានការឯកភាពជាលាយលក្ខណ៍អក្សរជាមុនពីនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ ក្នុងរយៈពេល ប្រាំ(៥)ថ្ងៃ គិតចាប់ពីថ្ងៃដែលសែកដែលត្រូវទូទាត់នោះ ត្រូវបានចេញក្រោមកម្មវិធីកែលម្អខាងមុខហាង។ ស្ថានភាពនៃការផ្តល់លទ្ធភាពសម្រួលការធ្វើដំណើរទាំងសម្រាប់ជនពិការ ដែលត្រូវទូទាត់សងប្រាក់វិញនៅក្រោមកម្មវិធីកែលម្អខាងមុខហាងនេះ គឺមិនអាចរុះរើវិញបាន ដោយគ្មានផែនការជំនួសដែលនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍បានត្រួតពិនិត្យជាមុនសិន។

**ជំនួយហិរញ្ញវត្ថុ**

ការផ្តល់ថវិកានេះ គឺជាការផ្គូផ្គងថវិកាជំនួយ ដែលសាលាក្រុងនឹងទូទាត់ប្រាក់សងថ្លៃជួលជុលកែលម្អដល់អ្នកដាក់ពាក្យសុំដូចខាងក្រោមៈ

- ទឹកប្រាក់ផ្គូផ្គង **៩០% ជាថវិកាជំនួយ ដែលមានទឹកប្រាក់រហូតដល់ ២០,០០០ ដុល្លារ សម្រាប់ការកែលម្អច្រកចូលអគារឲ្យងាយស្រួលសម្រាប់ជនពិការ**ផង ដោយរួមមានទាំងការបំពាក់ជម្រាល ជណ្តើរយោង គ្រឿងបំពាក់មាត់ទ្វារ និងមាត់ទ្វារបើកបានដោយស្វ័យប្រវត្តិ កន្លែងចតរថយន្តសម្រាប់ជនពិការផង និងស្លាកសញ្ញា។
- **ទឹកប្រាក់ជំនួយ ៥០% នឹងត្រូវផ្គូផ្គង ដែលមានចំនួនទឹកប្រាក់រហូតដល់ ១៥,០០០ ដុល្លារ សម្រាប់ការកែលម្អខាងមុខហាង** រួមទាំងមាត់បង្អួច លម្អតាមជញ្ជាំង ការបង្ហាញព័ត៌មានលម្អិតអំពីស្ថាបត្យកម្ម និងការស្តារឡើងវិញនូវមរតកប្រវត្តិសាស្ត្រ។
- **ទឹកប្រាក់ជំនួយ ៥០% នឹងត្រូវផ្គូផ្គង ដែលមានចំនួនទឹកប្រាក់រហូតដល់ ២,៥០០ ដុល្លារ សម្រាប់ស្លាកសញ្ញា** រួមទាំងស្លាកសញ្ញានៅតាមបង្អួច ភ្លើងបំភ្លឺ និងសំយាបហាង។

ថ្លៃរចនាតាមបែបស្ថាបត្យកម្ម អាចបូកបញ្ចូលទាំងថ្លៃសរុបនៃការកែលម្អដែលមានការយល់ព្រម ប៉ុន្តែមិនឲ្យលើស ៥,០០០ដុល្លារ នៃទឹកប្រាក់សរុបដែលត្រូវទូទាត់សងវិញនោះឡើយ។ គម្រោងណាមួយដែលស្នើសុំឲ្យមានការទូទាត់ប្រាក់សងវិញ ដែលមានទឹកប្រាក់លើសពី ២,៥០០ដុល្លារ ត្រូវតែមានផ្នែកខាងមុខហាងដែលអំណោយផលដល់ជនពិការ ឬដែលមានបំណងបង្កើតមួយ តាមរយៈកម្មវិធីកែលម្អខាងមុខហាងនេះ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ក៏យើងនឹងមិនផ្តល់ថវិកាជំនួយនេះលើសពី ២,៥០០ដុល្លារនោះឡើយ លើកលែងតែ និងទាល់តែទីតាំងអគារនោះ មានច្រកចូលដែលអំណោយផលដល់ជនពិការ ដែលអនុលោមតាមបទប្បញ្ញត្តិនៃការសម្រួលការធ្វើដំណើរសម្រាប់ជនពិការរបស់ជាតិ និងរដ្ឋ។ កម្មវិធីកែលម្អខាងមុខហាងនេះ នឹងផ្តល់ថវិកាជំនួយដើម្បីទូទាត់សងថ្លៃជួសជុលកែលម្អ ដល់អ្នកដាក់ពាក្យសុំ ដែលបានបង់ប្រាក់ទៅអ្នកម៉ៅការ និងអ្នកលក់របស់គាត់គ្រប់ចំនួនរួចហើយ ក្រោយគម្រោងនេះត្រូវបានកំណត់ថាបានបំពេញចប់សព្វគ្រប់តាមវិសាលភាពនៃសេវាដែលបានព្រមព្រៀងគ្នា និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ជាតិ រដ្ឋ និងមូលដ្ឋាន រវាងសាលាក្រុង និងអ្នកដាក់ពាក្យសុំ។ រាល់កិច្ចការណាដែលបានបង់ប្រាក់រួច ឬធ្វើនៅមុនចុះហត្ថលេខាលើកិច្ចសន្យា ឬ "សេចក្តីជូនដំណឹងអនុញ្ញាតឲ្យចាប់ដំណើរការកែលម្អ" ពីសាលាក្រុង នោះនឹងមិនត្រូវចាត់ទុកថាអាចទទួលយកបានសម្រាប់ការផ្តល់ប្រាក់ជំនួយដើម្បីទូទាត់សងវិញនេះនោះឡើយ។

## ពាក្យសុំ និងព័ត៌មាន

បើអ្នកចង់ចូលរួមក្នុងកម្មវិធីកែលម្អខាងមុខហាងនេះ សូមទាក់ទងការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងនាយកដ្ឋានផែនការ និងការអភិវឌ្ឍន៍ តាមលេខទូរស័ព្ទនេះ៖ 978-674-4252 ឬអ៊ីម៉ែល DoBizinLowell@Lowellma.gov។ សាលាក្រុងឡូវែល នឹងផ្តល់ជំនួយ និងសេវាពិសេស និងឯកសារជាលាយលក្ខណ៍អក្សរជាទម្រង់ផ្សេងពីនេះ និងកែសម្រួលសមស្របតាមគោលនយោបាយ និងនីតិវិធីសម្រាប់ជនពិការទៅតាមការស្នើសុំ។

**នីតិវិធី**

រាល់អ្នកដាក់ពាក្យសុំទាំងអស់ ត្រូវអនុវត្តតាមនីតិវិធីទៅតាមលំដាប់លំដោយដូចតទៅនេះ៖

1. អ្នកដាក់ពាក្យសុំ ត្រូវជួបជាមួយបុគ្គលិកផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច សម្រាប់ការពិភាក្សាអំពីគម្រោងបឋម និងដាក់ពាក្យ។ កិច្ចប្រជុំបន្ថែមជាមួយខាងអភិវឌ្ឍន៍សេដ្ឋកិច្ច និងមន្ត្រីឯទៀតរបស់សាលាក្រុង អាចត្រូវធ្វើជាចាំបាច់ ដើម្បីកពិភាក្សាអំពីកម្មវិធីកែលម្អខាងមុខហាង ព្រមទាំងជួបជាមួយក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត ដើម្បីជជែកអំពីដំណើរការផ្សេងៗ និងជម្រើសនៃរចនាបទ អាស្រ័យលើវិសាលភាពនៃការងារដែលបានស្នើ។
2. អ្នកគូសប្លង់រចនារបស់អ្នកដាក់ពាក្យសុំ ត្រៀមរៀបចំគូរប្លង់រចនា និងដាក់ទៅបុគ្គលផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីត្រួតពិនិត្យ និងឯកភាព។
3. ក្រោយប្លង់រចនានោះបានទទួលការយល់ព្រមហើយ អ្នកដាក់ពាក្យសុំមានពេល ៣០ថ្ងៃ ដើម្បីរកការដេញថ្លៃជាលាយលក្ខណ៍អក្សរចំនួនបី ពីអ្នកម៉ៅការ ដែលជាការចាំបាច់ ដើម្បីបំពេញកិច្ចការកែលម្អនេះ។ ការដៃថ្លៃពីអ្នកម៉ៅការនីមួយៗ ត្រូវតែចេញដោយអ្នកម៉ៅការដោយមានក្បាលលិខិតបញ្ជាក់អំពីក្រុមហ៊ុនម៉ៅការនោះ និងត្រូវប្រាប់អំពីថ្លៃឈ្នួលពាក់ព័ន្ធនឹងកិច្ចការនីមយ ឬសម្ភារៈដែលត្រូវដំឡើង។
4. ក្រោយខាងសាលាក្រុងឯកភាពលើឯកសារដេញថ្លៃនោះហើយ អ្នកដាក់ពាក្យសុំនឹងត្រូវចុះកិច្ចសន្យាសម្រាប់ទទួលប្រាក់ទូទាត់សងវិញនេះ ជាមួយសាលាក្រុងឡូវែល។ ចំនួនទឹកប្រាក់សរុបច្រើនបំផុត នឹងមានបញ្ជាក់នៅក្នុងកិច្ចសន្យា ដែលអាស្រ័យលើទឹកប្រាក់ទាបបំផុតក្នុងឯកសារដេញថ្លៃសម្រាប់គម្រោងកែលម្អ និងថវិកាជំនួយសម្រាប់កម្មវិធីនេះមានកំណត់។
5. កិច្ចប្រជុំមុនការសាងសង់ចាប់ផ្តើម នឹងត្រូវរៀបចំឡើង រវាងអ្នកដាក់ពាក្យសុំ និងមន្ត្រីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច អ្នកម៉ៅការដែលត្រូវបានជ្រើសរើស ស្ថាបត្យករគម្រោង និងមន្ត្រីសាលាក្រុង (ទៅតាមការចាំបាច់)។
6. មន្ត្រីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច នឹងផ្ញើ"សេចក្តីជូនដំណឹងអនុញ្ញាតឲ្យដំណើរការ"ទៅកាន់អ្នកដាក់ពាក្យសុំ ឬផ្ញើកិច្ចសន្យាដែលបានចុះហត្ថលេខារួច។ កិច្ចការទាំងឡាយណា ដែលបានបញ្ចប់នៅមុនទទួលបាន

សេចក្តីជូនដំណឹងនេះ ឬនៅមុនទទួលបានកិច្ចសន្យាដែលបានចុះហត្ថលេខារួចនេះ នឹងមិនទទួលបានការទូទាត់ប្រាកសងវិញនោះឡើយ។

7. អ្នកដាក់ពាក្យសុំមានរយៈពេល ៦០ថ្ងៃ ពីថ្ងៃអនុវត្តកិច្ចសន្យានេះ ដើម្បីចាប់ផ្តើមអនុវត្តគម្រោងកែលម្អដូចដែលបានព្រមព្រៀងគ្នា។ អ្នកដាក់ពាក្យសុំត្រូវផ្តល់ឯកសារអំពីលិខិតអនុញ្ញាតសម្រាប់ការសាងសង់ពាក់ព័ន្ធនឹងការព្រមព្រៀងឲ្យកែលម្អអគារនេះ ទៅមន្ត្រីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងត្រូវផ្តល់លិខិតបញ្ជាក់ដែលទទួលបានពីគម្រោងកែលម្អនេះផង។
8. អ្នកម៉ៅការនឹងសាងសង់គម្រោងកែលម្អនេះ ដូចដែលមានចែងជាក់លាក់នៅក្នុងប្លង់រចនាចុងក្រោយ។ ការផ្លាស់ប្តូរណាមួយដែលព្រមព្រៀងគ្នា និងម៉ៅការពីមុន ត្រូវតែមានលិខិតឯកភាពពីមុនពីមន្ត្រីពាក់ព័ន្ធរបស់សាលាក្រុង (ឧទាហរណ៍ នាយកដ្ឋានសេវាអភិវឌ្ឍន៍)។ វាអាស្រ័យលើអ្នកដាក់ពាក្យសុំ ក្នុងការជូនដំណឹងទៅកាន់មន្ត្រីសាលាក្រុងដែលពាក់ព័ន្ធ អំពីការផ្លាស់ប្តូរទាំងនេះ ដោយត្រូវសរសេរជាលាយលក្ខណ៍អក្សរ។
9. អ្នកដាក់ពាក្យសុំត្រូវជូនដំណឹងមន្ត្រីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចភ្លាម បើសិនជាមានបញ្ហាដោយចៃដន្យណាមួយកើតឡើង ក្នុងអំឡុងពេលនៃការសាងសង់ ដែលអាចធ្វើឲ្យខុសពីប្លង់រចនាចុងក្រោយ ដូចដែលបានព្រមព្រៀងគ្នារួចនោះ។ ការចុះទៅពិនិត្យដល់ទីតាំងផ្ទាល់ពីសំណាក់មន្ត្រីផ្នែកអភវិឌ្ឍន៍សេដ្ឋកិច្ច និងមន្ត្រីឯទៀតរបស់សាលាក្រុង (តាមការចាំបាច់) នឹងត្រូវធ្វើឡើងនៅមុនចាប់ដំណើរការសាងសង់នេះ ជាពិសេស បើប៉ះពាល់នឹងលទ្ធភាពអំណោយផលដល់ការធ្វើដំណើររបស់ជនពិការ។
10. អ្នកដាក់ពាក្យសុំជូនដំណឹងទៅមន្ត្រីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច នៅពេលគម្រោងរួចរាល់។
11. មន្ត្រីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងមន្ត្រីសាលាក្រុង (ឧទាហរណ៍គណៈកម្មការសាងសង់ រដ្ឋបាលក្រុមប្រឹក្សាភិបាលផ្នែកប្រវត្តិសាស្ត្រ) បញ្ជាក់ថាការកែលម្អនោះ គឺអនុលោមតាមប្លង់រចនាចុងក្រោយ និងចំណុចជាក់លាក់ រួមមានទាំងក្រមពាក់ព័ន្ធនឹងច្បាប់ស្តីពីជនពិការអាមេរិក និងរួមទាំងចំណុចជាក់លាក់ដែលបានជម្រាបទៅក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត ពាក់ព័ន្ធនឹងដំណើរការផ្សេងៗនៃពាក្យសុំ បើចាំបាច់។
12. ស្ថាបត្យករ និង/ឬ អ្នកម៉ៅការ ត្រូវដាក់លិខិតទៅមន្ត្រីខាងអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីទទួលស្គាល់អំពីការបានទូទាត់ប្រាក់គ្រប់ចំនួនពីអ្នកដាក់ពាក្យសុំ។ អ្នកដាក់ពាក្យសុំត្រូវផ្ញើឯកសារនៃវិកយបត្រ ដែលបានទូទាត់រួចទាំងអស់ រួមទាំងឯកសារចម្លងនៃសែកដែលបានលុបចោលវិញផង ឬឯកសាររបាយការណ៍ចំណាយប្រចាំខែពីកាតក្រេឌីត។

13. មន្ត្រីផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច ដាក់វិកយបត្រទាំងនេះ ទៅសាលាក្រុងឡូវែល ដើម្បី ចេញសែកសម្រាប់ការទូទាត់ប្រាក់សងវិញនេះ ដែលសែកនេះគឺត្រូវសរសេរទៅឈ្មោះអ្នកដាក់ពាក្យសុំ មិនមែនទៅស្ថាបត្យករ អ្នកម៉ៅការ ឬភាគីទីបីណាមួយឡើយ។ កម្មវិធីកែលម្អខាងមុខហាង សូមរក្សាសិទ្ធិក្នុងកែសម្រួល ពាក់ព័ន្ធនឹងលក្ខខណ្ឌ និងដែនកំណត់ ដូចមានចែងក្នុងគោលការណ៍ណែនាំនេះ។ មន្ត្រីសាលាក្រុងពីនាយដ្ឋានផែនការ និងអភិវឌ្ឍន៍ អាចដកប្រាក់នោះមកវិញ ក្នុងករណីចាំបាច់បើគម្រោងកែលម្អនោះ ធ្វើមិនត្រឹមត្រូវ មិនស្របតាមកូដ និងបើក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួលការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត អាចដកហូត ថវិកាជំនួយនោះវិញបាន បើការសាងសង់ដើម្បីអំណោយផលដល់ជនពិការនោះ ធ្វើមិនត្រឹមត្រូវ មិនស្របតាមកូដ និងបើខាងក្រុមប្រឹក្សាខាងស្ថាបត្យកម្មក្នុងការសម្រួល ការធ្វើដំណើរនៃរដ្ឋម៉ាសាឈូសេត មិនបានឯកភាព។

## ការលុបចោលកិច្ចសន្យា

សាលាក្រុងឡូវែលមានសិទ្ធិលុបចោលកិច្ចព្រមព្រៀងណាមួយ នៃកម្មវិធីកែលម្អខាងមុខហាងនេះ បើអ្នកចូលរួម ត្រូវបានរកឃើញថាបានប្រព្រឹត្តបំពានលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងគោលការណ៍ណែនាំទាំងនេះ ឬបើ គម្រោងនោះ ត្រូវបានចាប់ធ្វើនៅមុនមានកិច្ចព្រមព្រៀងជាមួយសាលាក្រុង៕